ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២៩)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ២៧៨ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦២ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖
- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦២ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ព្រហស្បតិ៍ ៨រោច ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៦២ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 34 |
| 1 | ក្រុមហ៊ុន យីង ដុង ស៊ូ ខូ អិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន យៃនធើរេនអឹកែរឹល (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុន អ៊ីហ្ស៊ី ឡាហ្វ ស៊ូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ឈាន ឈុន ហួង ជា ឯ ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ឈុនឌឹង ព្រីនធីង ខូ អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជាប់ប៊ីលយូ អ៊ែនដ៍ ឌី កម្ពុជា | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ហ៊្សូ ឈុន ស៊ូ | ភ្នំពេញ |
| 9 | ក្រុមហ៊ុន គ័ន ម៉ឹង ហៃនប៉ែក (ខេមបូឌា) អ៊ិនជាសស្រៀល ឯ.ក | កណ្តាល |
| 10 | ក្រុមហ៊ុន តុង ឆាយ ហ្សេសសិន តិចណូឡូជី | កណ្តាល |
| 11 | ក្រុមហ៊ុន ភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្តាល |
| 12 | ក្រុមហ៊ុន តើហ្វម វែល ហូលឌីង (ខេមបូឌា) លីមីធីត | កណ្តាល |
| 13 | ក្រុមហ៊ុន ដា រ៉ុង ព្រីនធីង & អឹមប្រយឌើរី | កណ្តាល |
| 14 | រោងចក្រផលិតកាបូប ហ៊ីលថប ឡាក់ហ្គេដ (ខេមបូឌា) ឯ.ក | កណ្តាល |
| 15 | ក្រុមហ៊ុន ខេនផាក (ខេមបូឌា) ឯ.ក | កណ្តាល |
| 16 | ក្រុមហ៊ុន សាប្រីណា (ខេមបូឌា) ហ្គាមិន ម៉ែនញ៉ូហ្វាក់ធឺរីន ខប | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន មីង ហៃ អេនធើប្រាយ(ខេមបូឌា)ឯ.ក. | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ហ្គ្រេត ភីស លីមីធីត | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន លីវ តាន អ៊ីនធើណេសិនណល ខេមបូឌាខូអិលធីឌី | កំពង់ស្ពឺ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន ហ៊ីរ៉ូតា (ខេមបូឌា) ហ្គាមិន | កំពង់ស្ពឺ |
| 21 | ក្រុមហ៊ុន ហុងកុងវីនហ្វៀរហ្គាមេន(ខេមបូឌា)អិលធីឌី | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុន សុទ្បាម៉ូដា (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | តាកែវ |
| 23 | ក្រុមហ៊ុន ប្រាយ ហ្វាស់ស៊ីង ឯ.ក | តាកែវ |
| 24 | ក្រុមហ៊ុន អើហ្វិកវីសិន ហ្វេកសិន ( ខេមបូឌា) ឯ.ក | តាកែវ |
| 25 | ក្រុមហ៊ុន តាកែវស៊ូ (ខេមបូឌា) ខូ.,អិលធីឌី | តាកែវ |
| 26 | ក្រុមហ៊ុន ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី | តាកែវ |
| 27 | ក្រុមហ៊ុន ស៊ីភីស៊ីធី អ៊ិនធើណេសិនណល | កំពង់ចាម |
| 28 | ក្រុមហ៊ុន អ៊ីលីត (ខេមបូឌា) | ស្វាយរៀង |
| 29 | ក្រុមហ៊ុន ដាប់ប៊ែលយូអ៊ីជីស៊ី ម៉ែនញ៉ូហ្វែកធឺរីង លីមីតធីត | ព្រះសីហនុ |
| 30 | ក្រុមហ៊ុន ហ័រហ្សូ ស៊ីធី ជុងមីង លេឌើរវែរ (ខេមបូឌា) ខមភេនី លីមីធីត | ព្រះសីហនុ |
| 31 | ក្រុមហ៊ុន ខេមបូឌាន យុនគុន ឯ.ក | ព្រះសីហនុ |
| 32 | ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ(ខេមបូឌា)ខូ,.អិលធីឌី_1 | កំពង់ឆ្នាំង |
| 33 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុធុន | បន្ទាយមានជ័យ |
| 34 | ក្រុមហ៊ុន ផេកធីក ខេមបូឌា ខូអិលធីឌី | សៀមរាប |
| ខ. វិស័យទេសចរណ៍ | | 28 |
| 35 | ក្រុមហ៊ុន បាអាតហ្គូត ឯ.ក | ភ្នំពេញ |
| 36 | សណ្ឋាគារ អូឡាំព្យា ស៊ីធី | ភ្នំពេញ |
| 37 | ក្រុមហ៊ុន តារាអ៊ែរផត | ភ្នំពេញ |
| 38 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 39 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 40 | ក្រុមហ៊ុន ហ៊្វូដឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 41 | សណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់ | ភ្នំពេញ |
| 42 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 43 | ក្រុមហ៊ុន ៥ អូសិន ខូអិលធីឌី | ភ្នំពេញ |
| 44 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 45 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 46 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |

| ល.រ | ឈ្មោះពេខចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 47 | ក្រុមហ៊ុន កូបេ យៃភែននីស វែស្ទវែន | សៀមរាប |
| 48 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 49 | ក្រុមហ៊ុន ឆេង រ៉េស៊ីដេន | សៀមរាប |
| 50 | សណ្ឋាគារ សារ៉ៃរីសត និង ស្ប៉ា | សៀមរាប |
| 51 | សណ្ឋាគារ លីនរតនះអង្គរ | សៀមរាប |
| 52 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 53 | ក្រុមហ៊ុន មេត្តារ៉េស៊ីដេន និង ស្ប៉ា | សៀមរាប |
| 54 | អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 55 | ក្រុមហ៊ុន ដីរេតព្យាណូ | សៀមរាប |
| 56 | ក្រុមហ៊ុន ហ្វេមីលី វូដេន ប៊ូទិក | សៀមរាប |
| 57 | ក្រុមហ៊ុន ម៉េម៉ រ អង្គរ | សៀមរាប |
| 58 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 59 | សណ្ឋាគារវិតូរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 60 | សណ្ឋាគារ អង្គរ | សៀមរាប |
| 61 | ក្រុមហ៊ុន ហាទៀន វីហ្គាស អេនធើធេនមេន រីហ្សត | កំពត |
| 62 | ក្រុមហ៊ុន រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |